ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
រាជបណ្ឌិត្យសភាកម្ពុជា

Royal Academy of Cambodia
Académie Royale du Cambodge

លេខៈ ០០៤ /២០ ស.ជ.ណ.

ថ្ងៃ ចន្ទ ៤រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០

# សេចក្តីជូនដំណឹង
## ស្តីពី
## ការប្រឡងជ្រើសរើសមន្ត្រីរាជការស៊ីវិលឱ្យចូលបម្រើការងារនៅរាជបណ្ឌិត្យសភាកម្ពុជា ក្របខណ្ឌទីស្តីការគណៈរដ្ឋមន្ត្រី ប្រចាំឆ្នាំ២០២០

**យោង** : លិខិតលេខ៥៧៤៥ មស.ក្រខ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩ របស់ក្រសួងមុខងារសាធារណៈ។

រាជបណ្ឌិត្យសភាកម្ពុជា សូមជម្រាបជូនដំណឹងដល់សាធារណជនមេត្តាជ្រាបថា រាជបណ្ឌិត្យសភាកម្ពុជា នឹងធ្វើការប្រឡងជ្រើសរើសមន្ត្រីក្របខណ្ឌថ្មី(ក្របខណ្ឌ **ក**) ចំនួន១៧(ដប់ប្រាំពីរ)នាក់ ដូចខាងក្រោម៖

**ក- មុខជំនាញ ចំនួន និងកម្រិតសញ្ញាបត្រ**

| ល.រ. | មុខជំនាញ | ចំនួន | កម្រិតសញ្ញាបត្រ |
|---|---|---|---|
| ១ | នីតិសាស្ត្រ | ១នាក់ | បណ្ឌិត |
| ២ | វិទ្យាសាស្ត្រសេដ្ឋកិច្ច | ១នាក់ | បណ្ឌិត |
| ៣ | ភាសាចិន | ២នាក់ | បរិញ្ញាបត្រជាន់ខ្ពស់ |
| ៤ | រដ្ឋបាលសាធារណៈ | ៣នាក់ | បរិញ្ញាបត្រ |
| ៥ | បុរាណវិទ្យា | ១នាក់ | បរិញ្ញាបត្រ |
| ៦ | ព័ត៌មានវិទ្យា | ១នាក់ | បរិញ្ញាបត្រ |
| ៧ | អគ្គិសនី | ១នាក់ | បរិញ្ញាបត្រ |
| ៨ | វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ | ២នាក់ | បរិញ្ញាបត្រ |
| ៩ | វិទ្យាសាស្ត្រព្រៃឈើ | ១នាក់ | បរិញ្ញាបត្រ |
| ១០ | អភិវឌ្ឍន៍ជនបទ | ១នាក់ | បរិញ្ញាបត្រ |
| ១១ | បរិស្ថាន | ១នាក់ | បរិញ្ញាបត្រ |
| ១២ | គីមីវិទ្យា | ១នាក់ | បរិញ្ញាបត្រ |
| ១៣ | ជីវវិទ្យា | ១នាក់ | បរិញ្ញាបត្រ |

**ខ- លក្ខខណ្ឌជ្រើសរើស**

- ត្រូវមានសញ្ជាតិខ្មែរ
- ត្រូវមានសញ្ញាបត្រស្របតាមជំនាញដែលជ្រើសរើស

អាសយដ្ឋាន ៖ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ - ប្រអប់សំបុត្រលេខ៥៣១ ភ្នំពេញ កម្ពុជា
Tel/Fax: (855) 23 890 180, Website: www.rac.gov.kh, E-mail: info@rac.gov.kh, P.O.Box 531 Phnom Penh, Cambodia

– ត្រូវមានអាយុត្រឹម ៣៥ឆ្នាំ ចំពោះបេក្ខជនដែលមានសញ្ញាបត្របរិញ្ញាបត្រ(ខែមករា ឆ្នាំ១៩៨៥)
– ត្រូវមានអាយុត្រឹម ៤០ឆ្នាំ ចំពោះបេក្ខជនដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់(ខែមករា ឆ្នាំ១៩៨០)
– ចំពោះមន្ត្រីរាជការ និងបេក្ខជនដែលមានសញ្ញាបត្របណ្ឌិតត្រូវបានលើកលែងលក្ខខណ្ឌអាយុ
– ចំពោះមន្ត្រីរាជការ ត្រូវមានការយល់ព្រមឱ្យផ្ទេរក្របខណ្ឌពីស្ថាប័នសាមី

**គ- វិញ្ញាសាប្រឡង**

– វិញ្ញាសាចំណេះដឹងទូទៅ(រយៈពេល២ម៉ោង)
– វិញ្ញាសាភាសាអង់គ្លេស(រយៈពេល១ម៉ោង និង៣០នាទី)
– វិញ្ញាសាជំនាញ(រយៈពេល២ម៉ោង និង០០នាទី)

**ឃ- សំណុំលិខិតសុំចុះឈ្មោះប្រឡង**

– សំណុំលិខិតដាក់ពាក្យប្រឡងចំនួន១(មួយ)ច្បាប់
– បេក្ខជនត្រូវភ្ជាប់មកនូវជាមួយៈ
  - សញ្ញាបត្រជំនាញ(បញ្ជាក់ផ្លូវការ) ចំនួន១(មួយ)ច្បាប់
  - សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ(បញ្ជាក់ផ្លូវការ) ចំនួន១(មួយ)ច្បាប់
  - សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ចំនួន១(មួយ)ច្បាប់
  - ច្បាប់ចម្លងសៀវភៅគ្រួសារ បណ្ណស្នាក់នៅ អត្តសញ្ញាណបណ្ណចំនួន១(មួយ)ច្បាប់
  - លិខិតថ្កោលទោស(ពេលប្រឡងជាប់) ចំនួន១(មួយ)ច្បាប់
  - លិខិតបញ្ជាក់សុខភាព(ពេលប្រឡងជាប់) ចំនួន១(មួយ)ច្បាប់

**ង- ទីកន្លែងលក់ និងទទួលពាក្យសុំចុះឈ្មោះប្រឡង**

បេក្ខជនត្រូវបំពេញសំណុំលិខិត និងដាក់ពាក្យសុំចុះឈ្មោះប្រឡងនៅផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋាន រាជបណ្ឌិត្យសភាកម្ពុជា ដែលមានអាសយដ្ឋាន មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ អគារF ជាន់ទី២ រៀងរាល់ម៉ោងធ្វើការ ចាប់ពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ វេលាម៉ោង១៧:០០នាទី។

**ច- កាលបរិច្ឆេទនិងមណ្ឌលប្រឡង( ជូនដំណឹងនៅពេលក្រោយ)**

ចំពោះព័ត៌មានលម្អិត បេក្ខជនអាចមកសាកសួរនៅផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋាន រាជបណ្ឌិត្យសភាកម្ពុជា ឬតាមរយៈលេខទូរសព្ទ ០១២ ៤៧៣ ៧០១/ ០១២ ៤៣៣ ៦៣៤ / ០៩២ ២០២ ៤១៧ រៀងរាល់ម៉ោងធ្វើការ។

**បញ្ជាក់ៈ**

- បេក្ខជនជាជនពិការ និងស្ត្រី ដែលមានសមត្ថភាពសមស្រប ត្រូវបានផ្តល់ជាអាទិភាព។
- តម្លៃពាក្យសុំចុះឈ្មោះប្រឡង ៥ ០០០ រៀល និងតម្លៃសុំសិទ្ធិប្រឡង ២០ ០០០ រៀល។

អាស្រ័យហេតុនេះ សូមបេក្ខជនទាំងអស់ជ្រាបព័ត៌មាន។

**ប្រធាន**

បណ្ឌិតសភាចារ្យ **សុខ ទូច**